# នីតិអន្តរជាតិសាធារណៈ
# PUBLIC INTERNATIONAL LAW

## មេរៀនទី ៦

LECTURE 6

## គោលការណ៍ទូទៅនៃនីតិអន្តរជាតិ

GENERAL PRINCIPLE OF INTERNATIONAL LAW

# មាតិកា

- កម្មវត្ថុនៃមេរៀន
- ផ្នែកទី១ សេចក្ដីផ្ដើម
- ផ្នែកទី២ គោលការណ៍ទូទៅនៃនីតិអន្តរជាតិ តាមមាត្រា៣៨ ICJ
  - សញ្ញាណទូទៅ
  - គោលគំនិតដើមនៃគោលការណ៍ទូទៅនៃនីតិអន្តរជាតិ
  - ខ្លឹមសារនៃគោលការណ៍ទូទៅនៃនីតិអន្តរជាតិ
- ផ្នែកទី៣ គោលការណ៍ទូទៅនៃនីតិអន្តរជាតិ
  - សញ្ញាណទូទៅ
  - គតិបណ្ឌិតគតិយុត្តជាមូលដ្ឋាន
- ផ្នែកទី៤ ប្រៀបធៀបគោលការណ៍ទូទៅនៃនីតិអន្តរជាតិ និងកិច្ចឯកតោភាគី
  - សញ្ញាណទូទៅ
  - អត្ថប្រយោជន៍នៃគោលការណ៍ទូទៅនៃនីតិ

# កម្មវត្ថុនៃមេរៀន

មេរៀនស្ដីអំពីគោលការណ៍ទូទៅនៃនីតិអន្តរជាតិ មានគោលបំណងឲ្យអ្នកសិក្សាបានស្វែងយល់ពី៖

- អ្វីទៅជាគោលការណ៍ទូទៅនៃនីតិអន្តរជាតិ?
- ការបកស្រាយផ្សេងៗគ្នានៃគោលការណ៍ទូទៅនៃនីតិអន្តរជាតិ
- ថាតើគោលគំនិតដើមនៃគោលការណ៍ទូទៅនៃនីតិអន្តរជាតិជាអ្វី?
- ស្វែងយល់ពីគុណសម្បត្តិនៃគោលការណ៍ទូទៅនៃនីតិអន្តរជាតិ

# ផ្នែកទី១ សេចក្តីផ្តើម

ដូចដែលបានសិក្សារួចមកហើយថា ប្រភពនៃនីតិអន្តរជាតិសាធារណៈមានចំនួនបួនសំខាន់ៗ ដែលក្នុងនោះរួមមានប្រភពចម្បង និងប្រភពបន្ទាប់ ឬ យើងអាចនិយាយបានផងដែរថា ប្រភពជាលាយលក្ខណ៍អក្សរ និងប្រភពមិនមែនជាលាយលក្ខណ៍អក្សរ។

# ផ្នែកទី១ សេចក្ដីផ្ដើម

ប្រភពចម្បងរួមមាន សន្ធិសញ្ញា និងទំនៀមទម្លាប់អន្តរជាតិ រីឯប្រភពបន្ទាប់បន្សំរួមមាន គោលការណ៍ទូទៅនៃនីតិអន្តរជាតិ និងកិច្ចឯកតោភាគី។ សូមបញ្ជាក់ថា កិច្ចឯកតោភាគីពុំមានបញ្ញត្តក្នុងមាត្រា៣៨ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ។

# ផ្នែកទី១ សេចក្ដីផ្ដើម

ដោយសារតែកិច្ចឯកតោភាគី មិនត្រូវបានបញ្ញត្តនៅក្នុងមាត្រា៣៨ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិទេ ប៉ុន្តែ កិច្ចឯកតោភាគីក៏ជាប្រភពមួយដែរនៃនីតិអន្តរជាតិសាធារណៈ ដូច្នេះនៅក្នុងមេរៀនទី៦ នេះយើងនឹងធ្វើការសិក្សាផងដែរពីកិច្ចឯកតោភាគី ដោយធ្វើជាការប្រៀបធៀបជាមួយនិងគោការណ៍ទូទៅនៃនីតិអន្តរជាតិ នៅក្នុងផ្នែកទី៤។

# ផ្នែកទី១ សេចក្ដីផ្ដើម

ដូចដែលបានលើកឡើងនៅក្នុងស្លាយទី៥ ផ្នែកទី១ សេចក្ដីផ្ដើមហើយ ប្រភពផ្សេងទៀតនៃនីតិអន្តរជាតិសាធារណៈរួមមាន គោលការណ៍ទូទៅនៃនីតិអន្តរជាតិ និងកិច្ចឯកតោភាគីក៏បានចូលរួមក្នុងការបង្កើតនីតិអន្តរជាតិផងដែរ គ្រាន់តែវាមិនមែនជាប្រភពចម្បប់តែប៉ុណ្ណោះ។

# ផ្នែកទី១ សេចក្ដីផ្ដើម

ប្រសិនបើសិក្សាឲ្យបានស៊ីជម្រៅ យើងពិនិត្យឃើញថា ទ្រឹស្ដីវិទូនៃនីតិអន្តរជាតិ និងយុត្តិសាស្ត្រ ក៏ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការចូលរួមអភិវឌ្ឍន៍នីតិ នៅក្នុងប្រព័ន្ធនៃនីតិអន្តរជាតិសាធារណៈ។ ប៉ុន្តែជាអកុសល ទាំងទ្រឹស្ដីវិទូ និងយុត្តិសាស្ត្រ មិនត្រូវបានគេរាប់បញ្ចូលថាជាប្រភពនៃនីតិអន្តរជាតិសធារណៈឡើយ គេបានចាត់ទុកវាថាគ្រាន់តែជាមធ្យោបាយសម្រាប់កំណត់ពីវិធាននៃនីតិតែប៉ុណ្ណោះ។

# ផ្នែកទី២ គោលការទូទៅនៃនីតិអន្តរជាតិតាមមាត្រា៣៨ ICJ

- សញ្ញាណទូទៅ

គោលការណ៍ទូទៅនៃនីតិ គឺជាគោលការណ៍មួយដែលទទួលស្គាល់ក្នុងប្រព័ន្ធច្បាប់នៃបណ្តាលរដ្ឋទាំងអស់។គោលការណ៍ទូទៅនៃនីតិ អាចត្រូវបានគេផ្តល់អត្ថន័យ ឬ ខ្លឹមសារជាច្រើនខុសៗពីគ្នា ប៉ុន្តែមានគោលដៅតែមួយក្នុងផ្តល់នូវអត្ថិភាពដល់គោលការណ៍ទ

# ផ្នែកទី២ គោលការទូទៅនៃនីតិអន្តរជាតិតាមមាត្រា៣៨ ICJ

- សញ្ញាណទូទៅ

ដោយគិតទៅដល់ការកំណត់នៃខ្លឹមសារខាងលើ គឺជាគោលការណ៍ទូទៅនៃនីតិ ដូចដែលមានបញ្ញត្តនៅក្នុងមាត្រា៣៨នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ឬ អាចនិយាយបានថា ជាគោលការណ៍ត្រូវបានលើកឡើងដោយទ្រឹស្តីវិទូនៃនីតិអន្តរជាតិសាធារណៈ។

# ផ្នែកទី២ គោលការទូទៅនៃនីតិអន្តរជាតិតាមមាត្រា៣៨ ICJ

- សញ្ញាណទូទៅ

គោលការណ៍ទូទៅនៃនីតិអន្តរជាតិ គឺប្រភពដ៏សំខានដែលថៅក្រមនៃតុលាការអន្តរជាតិ យកមកប្រើសម្រាប់ធ្វើជាសំអាងក្នុងការចេញនូវសេចក្តីវិនិច្ឆ័យរបស់ខ្លួនចំពោះរឿងក្តីដែលស្ថិនក្នុងសមត្ថកិច្ចរបស់ខ្លួន។

# ផ្នែកទី២ គោលការទូទៅនៃនីតិអន្តរជាតិតាមមាត្រា៣៨ ICJ

- សញ្ញាណទូទៅ

ទោះបីជា គេមិនបានដឹងពីវិសាលភាពគតិយុត្តរបស់វាក៏ដោយ នៅពេលដែលគេរតទៅរកគោលការណ៍នេះប្រើ ក៏គេសង្កេតឃើញថា គោលការណ៍ទូទៅនៃនីតិដូចជាមានទិសដៅអោបក្រសោបយក នូវនីតិអន្តរជាតិសាធារណៈទាំងមូល ឬ មើលទៅវាដូចជាគ្រោងឆ្អឹងនៃនីតិអន្តរជាតិសាធារណៈ។

# ផ្នែកទី២ គោលការទូទៅនៃនីតិអន្តរជាតិតាម មាត្រា៣៨ ICJ

- សញ្ញាណទូទៅ

ក្រោយពីសិក្សាមក វាបានបង្ហាញឲ្យឃើញថា ការប្រើប្រាស់ពាក្យគោលការណ៍ទូទៅមានខ្លឹមសារពីរប្រភេទ គឺខ្លឹមសារដូចដែលបានបញ្ញត្តដោយមាត្រា៣៨ លក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ និងខ្លឹមសារត្រូវបានប្រើប្រាស់ដោយអ្នកទ្រឹស្តីវិទូនៃនីតិអន្តរជាតិ។

# ផ្នែកទី២ គោលការទូទៅនៃនីតិអន្តរជាតិតាម មាត្រា៣៨ ICJ

- គោលគំនិតដើមនៃគោលការណ៍ទូទៅនៃនីតិអន្តរជាតិ មាត្រា៣៨ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ត្រូវបានយកចេញពីមាត្រា៣៨ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អចិន្ត្រៃយ៍អន្តរជាតិ ដោយពុំមានការកែប្រែទាំងលេខមាត្រា និងអត្ថន័យខ្លឹមសារ។

# ផ្នែកទី២ គោលការទូទៅនៃនីតិអន្តរជាតិតាមមាត្រា៣៨ ICJ

- គោលគំនិតដើមនៃគោលការណ៍ទូទៅនៃនីតិអន្តរជាតិ

ដោយខ្លាចរងនូវការរិះគន់មកលើខ្លួន ថាគ្មានសមត្ថភាព នៅពេលដែលតុលាការអន្តរជាតិមួយនេះ ទទួលបាននូវរឿងក្តីដែលដាក់មកឲ្យខ្លួនធ្វើការសម្រេចសេចក្តី ចំពេលកំពុងតែរៀបចំតាក់តែនូវមាត្រា៣៨។ ពេលនោះហើយ ដែលថៅក្រមនៃតុលាការនេះត្រូវប្រឈមមុខនឹងការខ្វះវិធានអនុវត្ត។

# ផ្នែកទី២ គោលការទូទៅនៃនីតិអន្តរជាតិតាមមាត្រា៣៨ ICJ

- គោលគំនិតដើមនៃគោលការណ៍ទូទៅនៃនីតិអន្តរជាតិ

ដូច្នេះ ដើម្បីជៀសផុតពីការចោទប្រកាន់ថា គ្មានសមត្ថភាពថៅក្រមនៃតុលាការអន្តរជាតិនេះ បានចោទសួរខ្លួនឯងថា តើថៅក្រមអន្តរជាតិ ត្រូវតែប្រកាសថាខ្លួនគ្មានសមត្ថកិច្ចដោយសារគ្មានវិធានអនុវត្តចំពោះរឿងក្តីនៅចំពោះមុខខ្លួន?

# ផ្នែកទី២ គោលការទូទៅនៃនីតិអន្តរជាតិតាមមាត្រា៣៨ ICJ

- គោលគំនិតដើមនៃគោលការណ៍ទូទៅនៃនីតិអន្តរជាតិ ដូច្នោះហើយ បានជាអ្នកតាក់តែងលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អចិន្ត្រៃយ៍អន្តរជាតិបានលើកឡើងថា ចៅក្រមអន្តរជាតិ អាចរត់រកគោលការណ៍ទូទៅនៃនីតិដែលទទួលស្គាល់ដោយរដ្ឋដែលគោរពច្បាប់ (រដ្ឋទទួលស្គាល់គោលការណ៍ទូទៅនៃនីតិ) ដោមិនគិតពីវិសាលភាពរបស់វាឡើយ។

# ផ្នែកទី២ គោលការទូទៅនៃនីតិអន្តរជាតិតាមមាត្រា៣៨ ICJ

- គោលគំនិតដើមនៃគោលការណ៍ទូទៅនៃនីតិអន្តរជាតិ

គោលការណ៍ទៅនៃនីតិ ដែលចៅក្រមអន្តរជាតិស្វែងរក គឺមិនតម្រូវឲ្យគោលការណ៍នោះ ត្រូវតែជាវិធានរួមនៃបណ្តាលរដ្ឋលើសកលលោកឡើយ តែអាចត្រឹមតែជាគោលការណ៍ដែលត្រូវបានរកបាននៅក្នុងស្មារតីរួម នៃបណ្តាលរដ្ឋមួយចំនួនក៏បាន។

# ផ្នែកទី២ គោលការទូទៅនៃនីតិអន្តរជាតិតាមមាត្រា៣៨ ICJ

- គោលគំនិតដើមនៃគោលការណ៍ទូទៅនៃនីតិអន្តរជាតិ

តាមពិតទៅគោលការណ៍ទូទៅនៃនីតិ វាត្រូវបានគេដកស្រង់ចេញពីស្មារតីរួមនៃច្បាប់ផ្ទៃក្នុងរបស់រដ្ឋណាមួយ ប៉ុន្តែវាអាចត្រូវបានធ្វើការផ្ទេរមកជាស្មារតីរួមនៃនីតិអន្តរជាតិ បានន័យថា វាត្រូវបានគេរកឃើញនៅក្នុងស្មារតីរួមដែលកើតចេញពីវិធាននៃប្រជាជាតិផ្សេងៗ ហើយចៅក្រមអន្តរជាតិយកវាមកប្រើដោយការប្រដូចទៅនិងការអនុវត្តរបស់ច្បាប់ផ្ទៃរបស់រដ្ឋ។

# ផ្នែកទី២ គោលការទូទៅនៃនីតិអន្តរជាតិតាមមាត្រា៣៨ ICJ

- ខ្លឹមសារនៃគោលការណ៍ទូទៅនៃនីតិអន្តរជាតិ

ការគ្រប់គ្រង់យុត្តិធម៌អន្តរជាតិល្អ ត្រូវបានគេយកចិត្តទុកដាក់យ៉ាងខ្លាំង ទោះនៅក្នុងសម័យកាលណាក៏ដោយ ហេតុនេះហើយ ថៅក្រមអន្តរជាតិតែងតែខិតខំស្វែងរកនូវគោលការណ៍ទូទៅ ពោលគឺធ្វើយ៉ាងណាដើម្បីឲ្យតុលាការអន្តរជាតិអាចដំណើរការទៅបាន ទោះវាជាវិធានជាសម្ភារៈ ឬ ជាវិធានបែបទម្រង់ក៏ដោយ។

# ផ្នែកទី២ គោលការទូទៅនៃនីតិអន្តរជាតិតាមមាត្រា៣៨ ICJ

- ខ្លឹមសារនៃគោលការណ៍ទូទៅនៃនីតិអន្តរជាតិ

វិធានដែលមានលក្ខណៈជាទម្រង់ ឬ ជាវិធានជាសម្ភារៈ គឺជាវិធានដែលត្រូវបានដកស្រង់ចេញពីនីតិកាតព្វកិច្ច ដែលជាអនុសញ្ញា ឬ ត្រូវបានដកស្រង់ចេញពីនីតិកាតព្វកិច្ចនៃទំនាស់ ហើយវិធាននេះអាចរីកចម្រើនទៅបាន លុះណាតែវិវាទដែលកើតមានឡើងពាក់ព័ន្ធនិងវាផងដែរ។

# ផ្នែកទី២ គោលការទូទៅនៃនីតិអន្តរជាតិតាមមាត្រា៣៨ ICJ

- ខ្លឹមសារនៃគោលការណ៍ទូទៅនៃនីតិអន្តរជាតិ

ឧទាហរណ៍ គោលការណ៍សុចរិតស្មោះត្រង់ PACTA SUNT SERVANDA គោលការណ៍នៃការជួសជុលសំណងនៃការខូចខាតដែលកើតចេញពីអំពើខុសច្បាប់ និងគោលការណ៍នៃការគ្រប់គ្រងយុត្តិធម៌ល្អ គឺគ្មានបុគ្គលណាម្នាក់អាចជាចៅក្រមផង និងជាភាគីនៃរឿងក្ដីផងបានទេ។

# ផ្នែកទី២ គោលការទូទៅនៃនីតិអន្តរជាតិតាមមាត្រា៣៨ ICJ

- ខ្លឹមសារនៃគោលការណ៍ទូទៅនៃនីតិអន្តរជាតិ

សញ្ញាណនៃនីតិអន្តរជាតិសាធារណៈ ក៏អាចត្រូវបានដកស្រង់ចេញពីគោលការណ៍ទូទៅនៃនីតិផងដែរ។ ជាពេលបច្ចុប្បន្ននេះ ដោយផ្តើមចេញពីនីតិផ្ទៃក្នុងរបស់រដ្ឋនានា គេអាចបង្កើតនូវវិធាននៃនីតិអង្គការអន្តរជាតិបាន។

# ផ្នែកទី២ គោលការទូទៅនៃនីតិអន្តរជាតិតាមមាត្រា៣៨ ICJ

- ខ្លឹមសារនៃគោលការណ៍ទូទៅនៃនីតិអន្តរជាតិ

តម្លៃនៃគោលការណ៍ទូទៅនៃនីតិមានការប្រែប្រួល នៅពេលដែលយុត្តិសាស្រ្តអន្តរជាតិ ត្រូវបានគេចាត់ទុកជាវិធានច្បាប់ត្រូវអនុវត្ត ហើយត្រូវបានបង្ហាញនៅក្នុងសាលក្រមរបស់តុលាការនៅពេលណា គឺវានឹងប្រែក្លាយទៅជាវិធានទំនៀមទម្លាប់ ឬ សន្ធិសញ្ញាបានយ៉ាងឆាប់រហ័ស។

# ផ្នែកទី៣ គោលការណ៍ទូទៅនៃនីតិអន្តរជាតិ

- សញ្ញាណទូទៅ

ការផ្តល់និយមន័យទៅលើគោលការណ៍ទូទៅនៃនីតិ នៅតែមានភាពស្មុកស្មាញ ទោះបីជាថៅក្រមអន្តរជាតិបានខិតខំប្រឹងប្រែងក្នុងការរត់រកនូវគោលការណ៍ទូទៅនៃនីតិអន្តរជាតិក្នុងគោលបំណងដើម្បីស្វែងរក និងផ្តល់យុត្តិធម៌ចំពោះភាគីវិវាទយ៉ាងណាក៏ដោយ។

# ផ្នែកទី៣ គោលការណ៍ទូទៅនៃនីតិអន្តរជាតិ

- សញ្ញាណទូទៅ

ការសិក្សាពីគោលការណ៍ទូទៅនៃនីតិអន្តរជាតិ គឺពិតជាមានលក្ខណៈទូលំទូលាយខ្លាំងណាស់ ដែលជាធ្វើឲ្យមានការលំបាកក្នុងកំណត់អំពីនិយមន័យវាខ្លាំងណាស់។ លើសពីនេះទៅទៀតបទដ្ឋានដែលទ្រឹស្តីវិទូយកមកប្រើ គឺពុំមានភាពចាំបាច់ប្រើពាក្យថា គោលការណ៍ទូទៅនៃនីតិ ដូចដែលចៅក្រមអន្តរជាតិប្រើនោះទេ ដូចជាពាក្យគតិបណ្ឌិតជាមូលដ្ឋាន ជាអាទ៍។

# ផ្នែកទី៣ គោលការណ៍ទូទៅនៃនីតិអន្តរជាតិ

- គតិបណ្ឌិតគតិយុត្តជាមូលដ្ឋាន

ប្រសិនបើយើងធ្វើការសិក្សាឲ្យបានស៊ីជម្រៅ យើងពិតជាអាចរកឃើញថា វិធានដែលចាត់ទុកថាជាគោលការណ៍ទូទៅបាន គឺមានតែវិធានដែលត្រូវបានថៅក្រមអន្តរជាតិបានធ្វើការដកស្រង់ចេញពីប្រភពផ្សេងៗ ដូចជាសន្ធិសញ្ញា និងទំនៀមទម្លាប់ ជាអាទិ៍។

# ផ្នែកទី៣ គោលការណ៍ទូទៅនៃនីតិអន្តរជាតិ

- គតិបណ្ឌិតគតិយុត្តជាមូលដ្ឋាន

ឧទាហរណ៍ គតិបណ្ឌិតគតិយុត្តជាមូលដ្ឋាននៃអភ័យឯកសិទ្ធិរដ្ឋ គតិបណ្ឌិតគតិយុត្តជាមូលដ្ឋានៃអធិបតេយ្យរដ្ឋ និងគោលការណ៍ជាមូលដ្ឋាននៃនីតិមនុស្សធម៌អន្តរជាតិ គោលការណ៍នៃការអនុវត្តសន្ធិសញ្ញាដោយស្មោះត្រង់ ជាអាទ៍។

# ផ្នែកទី៤ គ្រឿបគោលការណ៍ទូទៅនៃនីតិ និងកិច្ច ឯកតោភាគី

- សញ្ញាណទូទៅ

បើយើងនិយាយពីគោលការណ៍ទូទៅនៃនីតិ គឺវាពុំបានត្រូវ ឬ ត្រូវបានរៀបចំឲ្យចេញជារូបរាងពិតប្រាដតឡើយ។ មួយវិញទៀត គោលការណ៍ទូទៅនៃនីតិ គឺពុំចាំបាច់គោរពនូវលក្ខខណ្ឌសុពលភាពនោះក៏ទេដែរ។

# ផ្នែកទី៤ គោលការណ៍ទូទៅនៃនីតិ និងកិច្ចឯកតោភាគី

- សញ្ញាណទូទៅ

គោលការណ៍ទូទៅនៃនីតិ វាអាចមានអានុភាពទទៅបានអាស្រ័យទៅតាមការឲ្យតម្លៃទៅវាពីសំណាក់អ្នកប្រើប្រាស់វាតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត វាមានលក្ខណៈស្មុកស្មាញនូវក្នុងផ្តល់ឲ្យវានៅអត្ថន័យ ឬ និយមន័យពិតប្រាដ់តណាមួយឲ្យបានជាក់ច្បាស់ផងដែរ។

# ផ្នែកទី៤ ព្រៀបគោលការណ៍ទូទៅនៃនីតិ និងកិច្ចឯកតោភាគី

- សញ្ញាណទូទៅ

ប្រសិនបើយើងក្រឡេកមកមើល កិច្ចឯកតោភាគីដែលជាប្រភពមួយដែរនៃនីតិអន្តរជាតិសាធារណៈវិញ មានលក្ខណៈច្បាស់លាស់ ត្រូវមានតួអង្គក្នុងការបង្កើតវាឲ្យពិតប្រាដតព្រមទាំង វាត្រូវគោរពនូវលក្ខខណ្ឌសុពលភាពជាក់លាក់ថែមទៀតផង។

# ផ្នែកទី៤ គោលការណ៍ទូទៅនៃនីតិ និងកិច្ច ឯកតោភាគី

- អត្ថប្រយោជន៍នៃគោលការណ៍ទូទៅនៃនីតិ

ទោះវាមិនមានរូបរាងច្បាស់លាស់យ៉ាងណាក៏ដោយ ក៏ទាំងគោលការណ៍ទូទៅនៃនីតិ និងគោលការណ៍ទូទៅនៃនីតិអន្តរជាតិបានផ្តល់នូវផលប្រយោជន៍យ៉ាងច្រើន។ វាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងធានាបាននូវវិធានគតិយុត្ត ដែលលក្ខណៈល្អប្រើសើជាងមុនទោះមិនបានឥតខ្ចោះក៏ដោយ។

# ផ្នែកទី៤ ព្រៀបគោលការណ៍ទូទៅនៃនីតិ និងកិច្ចឯកតោភាគី

- អត្ថប្រយោជន៍នៃគោលការណ៍ទូទៅនៃនីតិ

វាបានចូលរួមចំណែកក្នុងអភិវឌ្ឍន៍ នូវវិធានទាំងថ្នាក់ជាតិ ថ្នាក់តំបន់ ក៏ដូចជាវិធានអន្តរជាតិឲ្យមានសុខដុមបនីយកម្ម និងអាចរក្សាបាននូវទំនាក់ទំនងល្អក្នុងសង្គម ក៏ដូចជាក្នុងសង្គមអន្តរជាតិទាំងមូល។

មេរៀនទី៦ ស្ដីពីគោលការណ៍ទូទៅនៃអន្តរជាតិ ត្រូវបានបញ្ចប់។ សូមអរគុណ សម្រាប់ការតាមដានដោយយកចិត្តទុកដាក់ពីសំណាក់អ្នកសិក្សាទាំងឡាយ។